តេឡេក្រាម ឯកសារមន្ត្រីសាធារណៈ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ...៩៨...សសរ......

# សេចក្តីសម្រេច
## ស្តីពី
## ការបង្កើតគណៈកម្មាធិការពិសេស ដើម្បីជំរុញការរៀបចំ និងការអនុវត្ត គម្រោងព្រែកជីកហ្វូណនតេជោ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០២១/០១៤ ចុះថ្ងៃទី១៥ ខែតុលា ឆ្នាំ២០២១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១២១/០១៨ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០២១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីភាពជាដៃគូរវាងរដ្ឋ និងឯកជន
- យោងសេចក្តីសម្រេចលេខ ១៨០ សសរ ចុះថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០២៣ ស្តីពីការកែសម្រួលគណៈកម្មការអន្តរក្រសួង ដើម្បីជំរុញដំណើរការអនុវត្តគម្រោងផ្លូវនាវាចរណ៍ "ព្រែកជីកហ្វូណនតេជោ"
- យោងតាមតម្រូវការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**ប្រការ១.**

ត្រូវបង្កើតគណៈកម្មាធិការពិសេស ដើម្បីជំរុញការរៀបចំ និងការអនុវត្តគម្រោងព្រែកជីកហ្វូណនតេជោ ដែលមានសមាសភាព ដូចខាងក្រោម៖

១- **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ប្រធាន

| | | |
|---|---|---|
| ២- ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** | ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | អនុប្រធាន |
| ៣- ឯកឧត្តម **ស៊ុន ចាន់ថុល** | ឧបនាយករដ្ឋមន្ត្រី អនុប្រធានទី១ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | អនុប្រធានប្រចាំការ |
| ៤- ឯកឧត្តម **សាយ សំអាល់** | ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | សមាជិក |
| ៥- ឯកឧត្តម **វង្សី វិស្សុត** | ឧបនាយករដ្ឋមន្ត្រីប្រចាំការ រដ្ឋមន្ត្រីទីស្ដីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ៦- ឯកឧត្តម **ឌិត ទីណា** | រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |
| ៧- ឯកឧត្តម **អ៊ាង សុផល្លែត** | រដ្ឋមន្ត្រីក្រសួងបរិស្ថាន | សមាជិក |
| ៨- ឯកឧត្តម **ថោ ជេដ្ឋា** | រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម | សមាជិក |
| ៩- លោកជំទាវ **ភឿង សកុណា** | រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | សមាជិក |
| ១០- ឯកឧត្តម **សុខ សូកេន** | រដ្ឋមន្ត្រីក្រសួងទេសចរណ៍ | សមាជិក |
| ១១- ឯកឧត្តម **ប៉េង ពោធិ៍នា** | រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន | សមាជិក និងជា ប្រធានលេខាធិការដ្ឋាន |
| ១២- ឯកឧត្តម **រស់ សីលវ៉ា** | រដ្ឋលេខាធិការ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ១៣- ឯកឧត្តម **ស្តើង សុខុម** | រដ្ឋលេខាធិការ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ១៤- ឯកឧត្តម **មាស សុខសេនសាន** | រដ្ឋលេខាធិការ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ១៥- ឯកឧត្តម **ជា វុទ្ធី** | អគ្គលេខាធិការគណៈកម្មាធិការវិនិយោគកម្ពុជា | សមាជិក |
| ១៦- ឯកឧត្តម **គង់ វិមាន** | អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | សមាជិក |
| ១៧- ឯកឧត្តម **អៀង វ៉េងស៊ុន** | រដ្ឋលេខាធិការ ក្រសួងសាធារណការ និងដឹកជញ្ជូន | សមាជិក |
| ១៨- ឯកឧត្តម **ឈួន ទិន** | រដ្ឋលេខាធិការ ក្រសួងសាធារណការ និងដឹកជញ្ជូន | សមាជិក |
| ១៩- ឯកឧត្តម **លុច្ឆ រចនា** | រដ្ឋលេខាធិការ និងជានាយកខុទ្ទកាល័យ ក្រសួងសាធារណការ និងដឹកជញ្ជូន | សមាជិក |
| ២០- ឯកឧត្តម **ផាន់ ចាន់ធុល** | រដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ | សមាជិក |
| ២១- ឯកឧត្តម **យស មុនីរ៉ាត់** | រដ្ឋលេខាធិការ ក្រសួងរ៉ែ និងថាមពល | សមាជិក |
| ២២- ឯកឧត្តម **លូ គឹមឈន់** | ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាប្រធានអគ្គនាយក កំពង់ផែស្វយ័តក្រុងព្រះសីហនុ | សមាជិក |
| ២៣- ឯកឧត្តម **ហ៊ី បាវី** | ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាប្រធានអគ្គនាយក កំពង់ផែស្វយ័តភ្នំពេញ | សមាជិក |
| ២៤- ឯកឧត្តម **ម៉ែន ធីរុទ្ធ** | អនុរដ្ឋលេខាធិការ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ២៥- ឯកឧត្តម **ស៊ឹម វីរៈ** | អនុរដ្ឋលេខាធិការ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ២៦- ឯកឧត្តម **ចាន់ តារា** | អនុរដ្ឋលេខាធិការ ក្រសួងសាធារណការ និងដឹកជញ្ជូន | សមាជិក |

| | | |
|---|---|---|
| ២៧- ឯកឧត្តម **សួន គារិទ្ធ** | អគ្គលេខាធិការរង គណៈកម្មាធិការវិនិយោគកម្ពុជា និងជានាយកខុទ្ទកាល័យ ឧបនាយករដ្ឋមន្ត្រី ស៊ុន ចាន់ថុល | សមាជិក |
| ២៨- ឯកឧត្តម **អ៊ឹម សិទ្ធីរ៉ា** | ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកអគ្គនាយក នៃអគ្គនាយកដ្ឋានដោះស្រាយផលប៉ះពាល់ដោយសារគម្រោងអភិវឌ្ឍន៍ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ២៩- ឯកឧត្តម **ស៊ូ សុជាតិ** | ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកអគ្គនាយក នៃនិយ័តករមូលបត្រកម្ពុជា | សមាជិក |
| ៣០- ឯកឧត្តម **ឱម ម៉ាក់ចារិទ្ធ** | អគ្គនាយក អគ្គនាយកដ្ឋានភាពជាដៃគូរវាងរដ្ឋ និងឯកជន ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ៣១- ឯកឧត្តម **ម៉ក់ ស៊ីដេត** | អគ្គនាយក អគ្គនាយកដ្ឋានដឹកជញ្ជូនផ្លូវទឹក ផ្លូវសមុទ្រ និងកំពង់ផែ ក្រសួងសាធារណការ និងដឹកជញ្ជូន | សមាជិក |
| ៣២- ឯកឧត្តម **កែន រដ្ឋា** | អគ្គនាយក អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ ក្រសួងសាធារណការ និងដឹកជញ្ជូន | សមាជិក |
| ៣៣- ឯកឧត្តម **ឈៀង ពេជ្រ** | អគ្គនាយក អគ្គនាយកដ្ឋានភស្តុភារកម្ម ក្រសួងសាធារណការ និងដឹកជញ្ជូន | សមាជិក |
| ៣៤- ឯកឧត្តម **គង់ សោភ័ណ្ឌ** | អភិបាលនៃគណៈអភិបាលខេត្តកណ្តាល | សមាជិក |
| ៣៥- ឯកឧត្តម **អ៊ុច គា** | អភិបាលនៃគណៈអភិបាលខេត្តតាកែវ | សមាជិក |
| ៣៦- ឯកឧត្តម **សោម ពិសិដ្ឋ** | អភិបាលនៃគណៈអភិបាលខេត្តកែប | សមាជិក |
| ៣៧- ឯកឧត្តម **ម៉ៅ ធនិន** | អភិបាលនៃគណៈអភិបាលខេត្តកំពត | សមាជិក |
| ៣៨- លោក **ហេង សុធី** | អគ្គនាយករង អគ្គនាយកដ្ឋានដឹកជញ្ជូនផ្លូវទឹក ផ្លូវសមុទ្រ និងកំពង់ផែ ក្រសួងសាធារណការ និងដឹកជញ្ជូន | សមាជិក |
| ៣៩- លោក **វ៉ាន់ សីហៈគីរី** | នាយកផែនការយុទ្ធសាស្ត្រ និងគម្រោងការ ក្រសួងរ៉ែ និងថាមពល | សមាជិក។ |

គណៈកម្មាធិការពិសេសនេះ អាចមានសមាសភាពបន្ថែមជាអនុប្រធាន ឬសមាជិក ដែលតំណាងឱ្យក្រសួង ស្ថាប័នពាក់ព័ន្ធផ្សេងទៀតតាមការចាំបាច់។ សមាសភាពបន្ថែមនេះត្រូវកំណត់ដោយសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល។

**ប្រការ២.**

គណៈកម្មាធិការពិសេសនេះ មានភារកិច្ច ដូចខាងក្រោម៖

- ពិនិត្យ និងសម្រេចអំពីនីតិវិធី ក្របខ័ណ្ឌគតិយុត្ត និងទម្រង់នៃការវិនិយោគលើគម្រោងព្រែកជីកហ្វូណនតេជោ
- រៀបចំអភិវឌ្ឍគម្រោងព្រែកជីកហ្វូណនតេជោ ឱ្យបានសម្រេចជាស្ថាពរ ដើម្បីសម្រេចបានផលប្រយោជន៍សង្គម-សេដ្ឋកិច្ច និងលើកកម្ពស់ប្រសិទ្ធភាពនៃការដឹកជញ្ជូនតាមផ្លូវទឹក និងផ្លូវសមុទ្ររបស់កម្ពុជា
- កំណត់នូវប្រភពហិរញ្ញប្បទានសម្រាប់ការរៀបចំ និងការអនុវត្តគម្រោងព្រែកជីកហ្វូណនតេជោ
- ចាត់ចែងរៀបចំ និងជំរុញអនុវត្តផែនការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធ និងប្រព័ន្ធឡូជីស្ទិកពាក់ព័ន្ធនឹងគម្រោងព្រែកជីកហ្វូណនតេជោ
- ចាត់ចែងរៀបចំ និងជំរុញអនុវត្តការងារផ្សេងទៀត ពាក់ព័ន្ធនឹងគម្រោងព្រែកជីកហ្វូណនតេជោ តាមការចាំបាច់។

**ប្រការ៣._**

អនុប្រធាន និងសមាជិកនៃគណៈកម្មាធិការពិសេសនេះ ត្រូវចូលរួមការប្រជុំតាមការអញ្ជើញរបស់ប្រធាន។ ក្នុងករណី ប្រធានអវត្តមានឬករណីចាំបាច់ ប្រធានអាចប្រគល់សិទ្ធិជូនអនុប្រធានណាម្នាក់ដឹកនាំកិច្ចប្រជុំជំនួស។

**ប្រការ៤._**

គណៈកម្មាធិការពិសេសនេះ មានក្រសួងសាធារណការ និងដឹកជញ្ជូន ជាលេខាធិការដ្ឋាន។

**ប្រការ៥._**

គណៈកម្មាធិការពិសេសនេះ មានសិទ្ធិបង្កើតអនុគណៈកម្មាធិការ ឬក្រុមការងារមួយចំនួន តាមការចាំបាច់ ដើម្បីជួយការងាររបស់ខ្លួន។

**ប្រការ៦._**

សេចក្ដីសម្រេចលេខ ១៨០ សសរ ចុះថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០២៣ ស្ដីពីការកែសម្រួលគណៈកម្មការអន្តរក្រសួង ដើម្បីជំរុញដំណើរការអនុវត្តគម្រោងផ្លូវនាវាចរណ៍ "ព្រែកជីកហ្វូណនតេជោ" និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្ដីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៧._**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តសេចក្ដីសម្រេចនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃព្រហស្បតិ៍ ១ រោច ខែ ពិសាខ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែ ឧសភា ឆ្នាំ២០២៤

**នាយករដ្ឋមន្ត្រី**

**សម្ដេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

**កន្លែងទទួល ៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្ដេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ ឯកឧត្ដមឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៧
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ